# សេចក្ដីសញ្ញាទាំងឡាយ

*ដោយ អែលឌើរ រ៉ុស្សែល អិម ណិលសុន*
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

បន្ទាប់ពីការចាត់តាំងថ្មីមួយឲ្យបង្កើតស្តេកដំបូងក្នុងទីក្រុង ម៉ូស្គូ ប្រទេសរុស្ស៊ី [1] បានមួយសប្តាហ៍មក ខ្ញុំបានចូលរួមសន្និសីទមណ្ឌលមួយក្នុងទីក្រុង សេន ភីទើរបើក ។

ខណៈពេលកំពុងនិយាយពីការដឹងគុណរបស់ខ្ញុំចំពោះពួកអ្នកផ្សាយសាសនា និងពួកអ្នកដឹកនាំក្នុងមូលដ្ឋានកាលពីមុន ដែលបានធ្វើឲ្យសាសនាចក្រក្នុងប្រទេសរុស្ស៊ីមានភាពរឹងមាំ ខ្ញុំបានលើកឡើងនូវឈ្មោះ វីយ៉ាឆេស្លាវ អេហ្វីម៉ូវ ។ គាត់ជាអ្នកប្រែចិត្តជឿជនជាតិរុស្ស៊ីដំបូងគេ ដែលបានក្លាយជាប្រធានបេសកកម្ម ។ គាត់ ហើយនិងភរិយាគាត់បានធ្វើបានយ៉ាងល្អក្នុងការចាត់តាំងនោះ ។ បន្ទាប់ពីពួកគាត់បានបញ្ចប់បេសកកម្មខ្លួនមិនយូរប៉ុន្មាន ប្រធាន អេហ្វីម៉ូវ បានទទួលមរណភាព ។[2] គាត់មានអាយុទើបតែ 52 ឆ្នាំប៉ុណ្ណោះ ។

ខណៈពេលកំពុងនិយាយពីស្វាមីភរិយាមួយគូនេះ ខ្ញុំបានទទួលអារម្មណ៍ឲ្យសួរដល់ក្រុមជំនុំ ថាតើបងស្រី អេហ្វីម៉ូវ មានវត្តមាននៅទីនោះដែរឬទេ ។ នៅខាងក្រោយបន្ទប់ នោះមានស្ត្រីម្នាក់ក្រោកឈរឡើង ។ ខ្ញុំបានអញ្ជើញគាត់ឲ្យមកកាន់វេទិកា ។ មែនហើយ ស្ត្រីម្នាក់នោះ គឺជាបងស្រី ហ្គាលីណា អេហ្វីម៉ូវ ។ គាត់បាននិយាយដោយមានការជឿជាក់ ហើយបានថ្លែងទីបន្ទាល់មួយ ដ៏មានឥទ្ធិពលពីព្រះអម្ចាស់ ពីដំណឹងល្អទ្រង់ និងពីសាសនាចក្រដែលបានស្តារឡើងវិញរបស់ទ្រង់ ។ គាត់ និងស្វាមីគាត់បានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។

គាត់បាននិយាយថា ពួកគាត់បានរួមរស់នឹងគ្នាជារៀងរហូត ។ ពួកគាត់នៅតែជាដៃគូផ្សព្វផ្សាយនឹងគ្នា ដោយគាត់នៅភពនេះ ហើយស្វាមីគាត់នៅភពមួយទៀត ។[3] ដោយទឹកភ្នែកនៃក្តីអំណរ គាត់បានអរគុណព្រះចំពោះសេចក្ដីសញ្ញាដ៏ពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធ ។ ខ្ញុំក៏បានស្រក់ទឹកភ្នែកផងដែរ ដោយយល់យ៉ាងពេញលេញថា ការរួបរួមដ៏អស់កល្បនៃស្វាមីភរិយាដ៏ស្មោះត្រង់នេះ គឺជាលទ្ធផលដ៏សុចរិតដែលកើតចេញពីការចុះ ការរក្សា និងការគោរពដល់សេចក្ដីសញ្ញាដ៏ពិសិដ្ឋ ។ ជំហានដ៏សំខាន់បំផុតមួយនៃសាសនាពិត គឺជាសេចក្ដីសញ្ញាដ៏ពិសិដ្ឋមួយ ។ ក្នុងភាសាច្បាប់ ជាទូទៅសេចក្ដីសញ្ញាមួយ គឺជាកិច្ចព្រមព្រៀងមួយរវាងភាគីពីរ ឬច្រើន ។

តែក្នុងផ្នែកខាងសាសនាវិញ សេចក្ដីសញ្ញាមួយ គឺមានសារៈសំខាន់លើសពីនេះទៅទៀត ។ វាជាការសន្យាមួយដ៏ពិសិដ្ឋជាមួយនឹងព្រះ ។ ទ្រង់ជាអ្នកកំណត់លក្ខខណ្ឌ ។ បុគ្គលម្នាក់ៗអាចជ្រើសរើសដើម្បីទទួលយកលក្ខខណ្ឌទាំងនោះ ។ បើបុគ្គលម្នាក់ទទួលយកលក្ខខណ្ឌនៃសេចក្ដីសញ្ញានោះ ហើយគោរពតាមក្រឹត្យវិន័យរបស់ព្រះ នោះគាត់ទទួលបានពរជ័យដោយភ្ជាប់មកជាមួយនឹងសេចក្ដីសញ្ញានោះ ។ យើងដឹងថា « កាលណាយើងបានព្រះពរណាមួយពីព្រះ នោះគឺដោយសារការគោរពដល់ក្រឹត្យវិន័យនោះ ដែលព្រះពរនោះផ្អែកទៅលើ » ។[4]

នៅគ្រប់សម័យកាល ព្រះបានបង្កើតសេចក្ដីសញ្ញាជាមួយនឹងកូនចៅទ្រង់ ។[5] សេចក្ដីសញ្ញាទ្រង់កើតមានពេញផែនការសង្គ្រោះទាំងមូល ហេតុដូច្នេះហើយវាជាផ្នែមួយនៃភាពពោរពេញនៃដំណឹងល្អទ្រង់ ។[6] ឧទាហរណ៍ ព្រះបានសន្យានឹងបញ្ជូនព្រះអង្គសង្គ្រោះមួយអង្គដល់កូនចៅទ្រង់[7] ដោយសុំត្រឡប់មកវិញនូវការគោរពរបស់ពួកគេចំពោះ ក្រឹត្យវិន័យទ្រង់ ។[8]

ក្នុងព្រះគម្ពីរប៊ីប យើងបានអានពីបុរសស្ត្រីក្នុងព្រះគម្ពីរសញ្ញាចាស់ដែលត្រូវបានស្គាល់ថាជាកូនចៅនៃសេចក្ដីសញ្ញា ។ តើសេចក្ដីសញ្ញាអ្វីទៅ ? « សេចក្ដីសញ្ញាដែលព្រះបានតាំងនឹងពួកអយ្យកោ [ ពួកគេ ] ដោយមានបន្ទូលនឹងលោកអ័ប្រាហាំថា អស់ទាំងគ្រួសារលើផែនដីនឹងបានពរដោយសារពូជឯង » ។[9]

ក្នុងព្រះគម្ពីរមរមនយើងបានអានពីមនុស្សក្នុងទ្វីបអាមេរិក ដែលត្រូវបានស្គាល់ថាជាកូនចៅនៃសេចក្ដីសញ្ញាផងដែរ ។[10] ព្រះអម្ចាស់ដែលរស់ឡើងវិញបានប្រាប់ពួកគេដូច្នេះថា ៖ « មើលចុះ អ្នករាល់គ្នាគឺជាកូនចៅនៃពួកព្យាការី ហើយអ្នករាល់គ្នា គឺជាវង្សអ៊ីស្រាអែល ហើយអ្នករាល់គ្នានៅក្នុងសេចក្ដីសញ្ញាដែលព្រះវរបិតាទ្រង់បានធ្វើជាមួយនឹងពួកអយ្យកោអ្នក ដោយព្រះបន្ទូលទៅលោកអ័ប្រាហាំថា ៖ ដោយសារពូជអ្នក នោះគ្រប់ទាំងពូជមនុស្សនៅផែនដីនឹងបានពរ » ។[11]

ព្រះអង្គសង្គ្រោះបានពន្យល់ពីសារៈសំខាន់នៃអត្តសញ្ញាណពួកគេក្នុងនាមជាកូនចៅនៃសេចក្ដីសញ្ញា ។ ទ្រង់បានមានបន្ទូលថា « ព្រះវរបិតា ដោយបានប្រោសយើងឲ្យរស់ឡើងវិញ ដល់អ្នករាល់គ្នាមុនគេបង្អស់ ហើយបានចាត់ឲ្យយើងមកប្រទានពរដល់អ្នករាល់គ្នាក្នុងការនាំអ្នករាល់គ្នាគ្រប់រូបចេញពីអំពើទុច្ចរិតរបស់ខ្លួន ការនេះ គឺមកពីអ្នករាល់គ្នាជាកូនចៅក្នុងសេចក្ដីសញ្ញា » ។ [12]

សេចក្ដីសញ្ញាដែលព្រះបានធ្វើនឹងលោកអ័ប្រាហាំ [13] ហើយក្រោយមកបានបញ្ជាក់ឡើងវិញជាមួយនឹងអ៊ីសាក [14] និងយ៉ាកុប [15] គឺជារឿងដ៏សំខាន់ខ្លាំងណាស់ ។ វាមាននូវការសន្យាមួយចំនួន ដូចជា ៖

- ព្រះយេស៊ូវ ដែលជាព្រះគ្រីស្ទនឹងប្រសូតតាមខ្សែស្រឡាយរបស់លោកអ័ប្រាហាំ ។
- ពូជពង្សរបស់លោកអ័ប្រាហាំនឹងមានចំនួនច្រើនលើសលុប ដោយមានសិទ្ធិទទួលបានការរីកចម្រើនដ៏អស់កល្ប ហើយក៏មានសិទ្ធិទទួលបព្វជិតភាពផងដែរ ។
- លោកអ័ប្រាហាំនឹងក្លាយជាឪពុកនៃជាតិសាសន៍ជាច្រើន ។
- ដែនដីជាក់លាក់ជាច្រើននឹងក្លាយជាកេរមរតកដល់ពូជពង្សលោក ។
- គ្រប់ជាតិសាសន៍លើផែនដីនឹងមានពរដោយសារពូជពង្សលោក ។ [16]
- ហើយសេចក្ដីសញ្ញានោះ នឹងមានភាពអស់កល្ប ---ទោះជាទាំង « ពាន់ដំណ »ក្ដី ។ [17]

ការសន្យាទាំងនេះមួយចំនួនត្រូវបានបំពេញរួចហើយ ការសន្យាផ្សេងទៀតកំពុងរង់ចាំដើម្បីបំពេញ ។ ខ្ញុំសូមដកស្រង់ចេញពីការព្យាករណ៍ដើមដំបូងក្នុងព្រះគម្ពីរមរមន ៖ « ឪពុកយើង [ លីហៃ ] មិនបាននិយាយអំពីពូជយើងតែប៉ុណ្ណោះទេ តែលោកព្រមទាំងបាននិយាយអំពីវង្សអ៊ីស្រាអែលទាំងអស់ដែរ ដោយចង្អុលដល់សេចក្ដីសញ្ញា ដែលនឹងត្រូវបានបំពេញ *នៅគ្រាចុងក្រោយ* គឺជាសេចក្ដីសញ្ញាដែលព្រះអម្ចាស់ទ្រង់បានធ្វើជាមួយនឹងលោកអ័ប្រាហាំ ជាអយ្យកោរបស់យើង » ។ [18] តើនោះមិនអស្ចារ្យទេឬ ? ប្រមាណជា 600 ឆ្នាំ *ពីមុន* ព្រះយេស៊ូវប្រសូតក្នុងភូមិបេថ្លេហិម ពួកព្យាការីបានដឹងថា នៅទីបំផុត សេចក្ដីសញ្ញា    របស់លោកអ័ប្រាហាំ នឹងត្រូវបានបំពេញតែ *នៅគ្រាចុងក្រោយ* ប៉ុណ្ណោះ ។

ដើម្បីជួយបំពេញការសន្យានេះ ព្រះអម្ចាស់បានលេចមកក្នុងគ្រាចុងក្រោយដើម្បីរំឭកសេចក្ដីសញ្ញារបស់លោកអ័ប្រាហាំ ។ លោកចៅហ្វាយបានប្រកាសទៅកាន់ព្យាការីយ៉ូសែប ស្ម៊ីធថា ៖  លោកអ័ប្រាហាំ បានទទួលសេចក្ដីសន្យាអំពីពូជរបស់លោក និងអំពីផលនៃពោះរបស់លោក ---គឺអ្នករាល់គ្នាចេញពីពោះ អ្នកនោះហើយ គឺឈ្មោះថា យ៉ូសែប ... ។ សេចក្ដីសន្យានេះក៏ជាសេចក្ដីសន្យាដល់អ្នកដែរ ពីព្រោះអ្នករាល់គ្នាជាពូជពីលោកអ័ប្រា-ហាំ » ។ [19]

ដោយការរំឭកឡើងវិញនៃការសន្យានេះ យើងបានទទួលបព្វជិតភាពបរិសុទ្ធ និងដំណឹងល្អដ៏អស់កល្ប ដូចជាប្រជាជនកាលពីបុរាណដែរ ។ យើងមានសិទ្ធិដើម្បីទទួលបានភាពពោរពេញនៃដំណឹងល្អ រីករាយនឹងពរជ័យនៃបព្វជិតភាព និងមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ពរជ័យដ៏ធំបំផុតរបស់ព្រះ ---នោះគឺជីវិតដ៏អស់កល្ប ។ [20]

មានយើងមួយចំនួន គឺជាពូជពិតនៃលោកអ័ប្រាហាំ អ្នកផ្សេងទៀតត្រូវបានប្រមូលចូលក្នុងគ្រួសារលោកដោយការសុំចិញ្ចឹម ។ ព្រះអម្ចាស់មិនធ្វើឲ្យមានភាពខុសប្លែកគ្នាឡើយ ។ [21] យើងទាំងអស់គ្នាទទួលពរជ័យដែលបានសន្យាទាំងនេះ ---បើយើងស្វែងរកព្រះអម្ចាស់ ហើយគោរពព្រះបញ្ញត្តិទ្រង់ ។ [22] តែបើយើងមិនធ្វើតាម នោះយើងនឹងបាត់បង់ពរជ័យនៃសេចក្ដីសញ្ញានោះ ។ [23] ដើម្បីជួយយើង សាសនាចក្រទ្រង់បានផ្ដល់ពររបស់លោកអយ្យកោ ដើម្បីផ្ដល់ការយល់ដឹងមួយឲ្យអ្នកទទួលម្នាក់ៗ ពីអនាគតខ្លួន ក៏ដូចជាទំនាក់ទំនងអតីតកាល រួមទាំងការប្រកាសមួយនៃខ្សែស្រឡាយទៅកាន់លោកអ័ប្រាហាំ អ៊ីសាក និងយ៉ាកុបផងដែរ ។ [24]

បងប្អូនប្រុសនៃសេចក្ដីសញ្ញាមានសិទ្ធិដើម្បីផ្ដល់គុណសម្បត្តិគ្រប់គ្រាន់សម្រាប់សម្បថ និងសេចក្ដីសញ្ញានៃបព្វជិតភាព ។ [25] បើអ្នក « ស្មោះត្រង់ក្នុងកាលបានបព្វជិតភាពទាំងពីរនេះ ...ហើយបានដំកើងការហៅរបស់[អ្នក] នោះអ្នកត្រូវបានញែកជាបរិសុទ្ធ ដោយព្រះវិញ្ញាណចំពោះការសាងរូបកាយរបស់ [អ្នក] ជាថ្មី » ។ [26]

នោះមិនទាន់អស់នៅឡើយទេ ។ បុរសដែលទទួលបព្វជិតភាពដោយសក្ដិសម នោះទទួលព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយអ្នកណាដែលទទួលព្រះអម្ចាស់ នោះទទួលព្រះជាព្រះបិតា ។ [27] ហើយអ្នកណាដែលទទួលព្រះវរបិតា នោះនឹងទទួលនូវអ្វីៗទាំងអស់ដែលទ្រង់មាន ។ [28] ពរជ័យដ៏អស្ចារ្យដែលមានដល់បុរសស្ត្រី និងកុមារដ៏សក្ដិសមក្នុងលោកិយទាំងអស់ គឺចេញពីសម្បថ និងសេចក្ដីសញ្ញានេះ ។

យើងមានទំនួលខុសត្រូវជួយបំពេញសេចក្តីសញ្ញាលោកអ័ប្រាហាំ ។ ពូជពង្សរបស់យើងត្រូវបានតែងតាំងពីមុនមក ហើយបានរៀបចំដើម្បីប្រទានពរដល់មនុស្សទាំងអស់ក្នុងពិភពលោកនេះ ។[29] នោះជាហេតុផលដែលកាតព្វកិច្ចបព្វជិតភាព រួមបញ្ចូលទាំងកិច្ចការផ្សាយសាសនាផងដែរ ។ បន្ទាប់ពីប្រមាណជា 4,000 ឆ្នាំ នៃការរំពឹងទុក និងការរៀបចំខ្លួន នេះជាគ្រាដែលបានតាំង ជាពេលដែលដំណឹងល្អត្រូវបាននាំទៅកាន់គ្រប់ជាតិសាសន៍ក្នុងផែនដី ។ នេះជាគ្រានៃការប្រមូលផ្តុំសាសន៍អ៊ីស្រាអែល ដែលបានសន្យា ។ ហើយយើងត្រូវតែចូលរួម ! តើនោះមិនគួរឲ្យរំភើបទេឬ ? ព្រះអម្ចាស់កំពុងពឹងផ្អែកលើយើង និងកូនប្រុសយើង ---ហើយទ្រង់មានអំណរជាខ្លាំងសម្រាប់កូនស្រីយើង ---ដែលបម្រើដោយសក្តិសមជាពួកអ្នកផ្សាយសាសនាក្នុងគ្រាដ៏អស្ចារ្យនេះនៃការប្រមូលផ្តុំសាសន៍អ៊ីស្រាអែល ។

ព្រះគម្ពីរមរមនគឺជាភស្តុតាងដ៏ជាក់ស្តែងមួយថា ព្រះអម្ចាស់បានចាប់ផ្តើមប្រមូលកូនចៅ នៃសេចក្តីសញ្ញារបស់ទ្រង់ ដែលជាសាសន៍អ៊ីស្រាអែល ។[30] ព្រះគម្ពីរនេះ ត្រូវបានសរសេរសម្រាប់ជំនាន់យើង បានថែងពីគោលបំណងមួយរបស់ខ្លួនថា « អ្នករាល់គ្នាអាចដឹងថាសេចក្តីសញ្ញាដែលព្រះវរបិតាទ្រង់បានធ្វើជាមួយនឹងកូនចៅអ៊ីស្រាអែល ...កំពុងតែចាប់ផ្តើមបំពេញ ...ត្បិតមើលចុះ ព្រះអម្ចាស់ទ្រង់នឹងនឹកចាំដល់សេចក្តីសញ្ញាដែលទ្រង់បានធ្វើជាមួយនឹងរាស្ត្រទ្រង់ ជាវង្សអ៊ីស្រាអែល » ។[31]

ពិតណាស់ ព្រះអម្ចាស់មិនភ្លេចឡើយ ! ទ្រង់បានប្រទានពរដល់យើង និងមនុស្សដទៃទៀតទូទាំងពិភពលោកជាមួយនឹងព្រះគម្ពីរមរមន ។ គោលបំណងមួយនៃព្រះគម្ពីរនេះគឺ ដើម្បីជា « ការបរិវត្តន៍ដល់សាសន៍យូដា និងសាសន៍ដទៃថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ » ។[32] វាជួយយើងឲ្យចុះសេចក្តីសញ្ញាជាមួយនឹងព្រះ ។ អញ្ជើញយើងឲ្យចងចាំទ្រង់ ហើយស្គាល់ព្រះរាជបុត្រាសំណប់ទ្រង់ ។ ជាសក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ ។

កូនចៅនៃសេចក្តីសញ្ញាមានសិទ្ធិដើម្បីទទួលគោលលទ្ធិរបស់ទ្រង់ និងដើម្បីស្គាល់ពីផែនការសង្គ្រោះ ។ ពួកគេ*ស្នើសុំ* សិទ្ធិនោះដោយការចុះសេចក្តីសញ្ញាដ៏សំខាន់ និងដ៏ពិសិដ្ឋ ។ ព្រិកហាំ យ៉ង់មានប្រសាសន៍ថា ៖ « រាល់ពួកបរិសុទ្ធថ្ងៃចុងក្រោយចូលក្នុងសេចក្តីសញ្ញាថ្មី ហើយអស់កល្បជានិច្ច ពេលពួកគេចូលក្នុងសាសនាចក្រនេះ ... ។ ពួកគេចូលក្នុងសេចក្តីសញ្ញាថ្មី ហើយអស់កល្បជានិច្ចដើម្បីគាំទ្រ និងពង្រឹងដល់នគរព្រះ» ។[33] ពួកគេ*រក្សា* សេចក្តីសញ្ញាដោយគោរពព្រះបញ្ញត្តិទ្រង់ ។

នៅពេលធ្វើបុណ្យជ្រមុជទឹក យើងបានចុះសេចក្តីសញ្ញាថានឹងបម្រើព្រះអម្ចាស់ ហើយគោរពព្រះបញ្ញត្តិទ្រង់ ។[34] ពេលយើងទទួលទានសាក្រាម៉ង់ យើងរំឭកនូវសេចក្តីសញ្ញានោះ ហើយប្រកាសពីឆន្ទៈយើងដើម្បីលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។ តាមរបៀបនេះ យើងត្រូវបានរក្សាទុកជាបុត្រាបុត្រីទ្រង់ ហើយត្រូវបានស្គាល់ថាជាបងប្អូនប្រុសស្រី ។ ទ្រង់ជាបិតានៃជីវិតថ្មីយើង ។[35] ជាងនេះទៀត ក្នុងព្រះវិហារបរិសុទ្ធ យើងអាចចូលរួមគ្រងមរតកពរជ័យនៃការមានគ្រួសារអស់កល្បមួយ ដូចដែលបានសន្យាដល់លោកអ័ប្រាហាំ អ៊ីសាក យ៉ាកុប និងពូជពង្សរបស់គេផងដែរ ។[36] ដូច្នេះ អាពាហ៍ពិពាហ៍សេឡេស្ទាលគឺជាសេចក្តីសញ្ញានៃភាពតម្កើងឡើង ។

ពេលយើងដឹងថា យើងជាកូនចៅនៃសេចក្តីសញ្ញា នោះយើងដឹងថាយើងជានរណា និងអ្វីដែលព្រះរំពឹងចង់បានពីយើង ។[37] ក្រឹត្យវិន័យទ្រង់ត្រូវបានឆ្លាក់ក្នុងដួងចិត្តយើង ។[38] ទ្រង់ជាព្រះយើង ហើយយើងជារាស្ត្រទ្រង់ ។[39] កូនចៅនៃសេចក្តីសញ្ញាដ៏មុតមាំ គឺមានភាពខ្ជាប់ខ្ជួន សូម្បីតែនៅក្នុងគ្រានៃទុក្ខវេទនាក្តី ។ ពេលគោលលទ្ធិនោះ ត្រូវបានបណ្តុះយ៉ាងជ្រៅក្នុងដួងចិត្តយើង សូម្បីតែចំណងនៃសេចក្តីស្លាប់ ក៏ងាយនឹងទទួលបានដែរ ហើយការអំណត់ខាងវិញ្ញាណរបស់យើងនឹងត្រូវបានពង្រឹង ។

ការសរសើរដ៏ធំធេងបំផុតដែលអាចទទួលបានក្នុងជីវិតនេះ គឺពេលបានដឹងថាអ្នកជាអ្នកគោរពសេចក្តីសញ្ញាម្នាក់ ។ រង្វាន់សម្រាប់អ្នកគោរពសេចក្តីសញ្ញា គឺនឹងទទួលបាន ទាំងក្នុងជីវិតនេះ និងជីវិតខាងមុខ ។ ព្រះគម្ពីរបានប្រកាសថា « អ្នករាល់គ្នា គិតពិចារណាអំពីស្ថានភាពដ៏មានពរ និងរីករាយនៃអស់អ្នកដែលកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។ ត្បិតមើលចុះ ពួកគេបានពរគ្រប់យ៉ាង... ហើយបើសិនជាពួកគេ រក្សាការស្មោះត្រង់ដរាបដល់ចុងបំផុត នោះពួកគេនឹងត្រូវបានទទួលនៅស្ថានសួគ៌ [ហើយ]...រស់នៅជាមួយនឹងព្រះក្នុងស្ថានភាពសុភមង្គលដ៏មិនចេះចប់មិនចេះហើយ »។[40]

ព្រះមានព្រះជន្មរស់ ។ ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។ សាសនាចក្រទ្រង់បានស្តារឡើងវិញដើម្បីប្រទានពរដល់មនុស្សទាំងអស់ ។ ប្រធាន ថូម៉ាស អេស ម៉នសុន ជាព្យាការីរបស់ទ្រង់សព្វថ្ងៃនេះ ។ ហើយក្នុងនាមជា កូនចៅនៃសេចក្តីសញ្ញា*ដ៏ស្មោះត្រង់* យើងនឹងទទួលបានពរជ័យនាពេលនេះ និងជារៀងរហូត ។ ខ្ញុំសូមទីបន្ទាល់ដូច្នេះក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. ស្តេកស្រុីម្ហូត្រូវបានបង្កើតឡើងនៅថ្ងៃអាទិត្យ ទី 5 ខែ មិថុនា ឆ្នាំ 2011 ។

2. គាត់ជាប្រធាននៃបេសកកម្មយេកាទើរីងប៊ីហ្គរុស្ស៊ីពី ឆ្នាំ 1995 ដល់ឆ្នាំ 1998 ។ គាត់ទទួលមរណភាពនៅថ្ងៃទី 25 ខែ កុម្ភៈ ឆ្នាំ 2000 ។

3. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 138:57 ។

4. គោលលទ្ធិ និងសេចក្ដីសញ្ញា 130:21 ។

5. ឧទាហរណ៍ បន្ទាប់ពីទឹកជំនន់ដំធំ ទ្រង់បានថ្លែងថា « ធ្នូនឹងត្រូវបានដាក់នៅនាពពក ហើយយើងនឹងចងចាំពីសេចក្ដីសញ្ញាដែលយើងបានតាំងនឹងអ្នក ... នោះនឹងគ្មានទឹកជន់ឡើងលិចផែនដី ដើម្បីបំផ្លាញគ្រប់ទាំងសាច់ទៀតឡើយ » (Genesis 9:14--15, footnote b; from Joseph Smith Translation, Genesis 9:20) ។

6. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 133:57 ។

7. សូមមើល យ៉ូហាន 3:16 ។

8. សូមអ័ប្រាហាំ 3:25 ។

9. កិច្ចការ 3:25 ។

10. សូមមើល នីហ្វៃទី3 20:26 ។

11. នីហ្វៃទី3 20:25 ។

12. នីហ្វៃទី3 20:26 ។

13. សូមមើលលោកុប្បត្តិ 17:1--10, 19, លេវីវិន័យ 26:42, កិច្ចការ 3:25, Bible Dictionary, « Abraham, Covenant of » ។

14. សូមមើល លោកុប្បត្តិ 26:1--5, 24 ។

15. សូមមើល លោកុប្បត្តិ 28:1--4, 10--14; 35:9--13; 48:3--4 ។

16. សូមមើលសេចក្ដីយោងដែលបានដាក់ខាងលើក្នុងកំណត់ចំណាំចុងបញ្ចប់ 13--15 ។

17. ចោទិយកថា 7:9, របាក្សត្រទី1 16:15, ទំនុកដំកើង105:8 ។

18. នីហ្វៃទី1 15:18 ការបញ្ជាក់បានដាក់បន្ថែម

19. គោលលទ្ធិ និងសេចក្ដីសញ្ញា 132:30--31 ។ ព្រះអម្ចាស់ក៏បានប្រាប់ដល់ព្យាការីយ៉ូសែប ស៊្មីធផងដែរថា ៖ « ដូចជាយើងមានព្រះបន្ទូលដល់លោកអ័ប្រាហាំអំពីពូជមនុស្សទាំងឡាយនៅផែនដីយ៉ាងណា នោះយើងក៏មានបន្ទូលដល់យ៉ូសែប ជាអ្នកបម្រើយើងយ៉ាងនោះដែរថា៖ ដោយសារអ្នកនិងដោយសារពូជអ្នក នោះគ្រួសារមនុស្សនៅផែនដីនឹងបានពរ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា 124:58 ) ។

20. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា14:7 ។

21. សូមមើលកិច្ចការ 10:34--35 ។

22. សូមមើលនិក្ខមនំ 19:5 ។

23. ព្រះគម្ពីរបានប្រកាសថា « យើងជាព្រះអម្ចាស់ជាប់សន្យា កាលណាអ្នករាល់គ្នាប្រព្រឹត្តតាមអ្វីដែលយើងមានព្រះបន្ទូល ប៉ុន្តែកាលណាអ្នករាល់គ្នាមិនប្រព្រឹត្តតាមអ្វីដែលយើងមានព្រះបន្ទូលទេ នោះអ្នករាល់គ្នាពុំមានសេចក្ដីសន្យាឡើយ »( គោលលទ្ធិ និងសេចក្ដីសញ្ញា 82:10 ) ។

24. នៅថ្ងៃទី 21 ខែ កញ្ញា ឆ្នាំ 1823 គំនិតនៃសេចក្ដីសញ្ញានេះត្រូវបានបើកសម្ដែងជាលើកដំបូងទៅដល់ព្យាការីយ៉ូសែប ស៊្មីធ ។ បន្ទាប់មក ទេវតា មរ៉ូណៃបានប្រកាសថា អេលីយ៉ាជាព្យាការីនឹងមកក្នុងនាមជាអ្នកនាំសារពីស្ថានសួគ៌ ដើម្បីបណ្ដុះក្នុងដួងចិត្តកូនចៅទាំងនោះនូវចំណេះដឹងនៃការសន្យាដែលធ្វើនឹងពួកអយ្យកោនៃវង្សអ៊ីស្រាអែល ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 2:1--3 ) ។

25. សូមមើលគោលលទ្ធិនិងសេចក្ដីសញ្ញា 84:33--34, 39--40 ។

26. គោលលទ្ធិ និងសេចក្ដីសញ្ញា 84:33 ។

27. សូមមើលគោលលទ្ធិ និងសេចក្ដីសញ្ញា 84:35, 37 ។

28. សូមមើលគោលលទ្ធិ និងសេចក្ដីសញ្ញា 84:38 ។

29. សូមមើលអាលម៉ា 13:1—9 ។

30. សូមមើល នីហ្វៃទី3  29 ។

31. នីហ្វៃទី3 29:1, 3 ។

32. ទំព័រចំណងជើងព្រះគម្ពីរមរមន ៖ សក្ខីបទមួយទៀតនៃព្រះយេស៊ូវគ្រីស្ទ ។

33. *Teachings of Presidents of the Church: Brigham Young* ( ឆ្នាំ 1997 ) ទំព័រ 62 ។

34. សូមមើលគោលលទ្ធិ និងសេចក្ដីសញ្ញា 20:37 ។

35. « យើងនិយាយអំពីព្រះគ្រីស្ទ យើងអររីករាយក្នុងព្រះគ្រីស្ទ យើងផ្សាយអំពីព្រះគ្រីស្ទ យើងព្យាករអំពីព្រះគ្រីស្ទ ...ដើម្បីឲ្យកូនចៅយើងអាចដឹងថាតើត្រូវស្វែងរកប្រភពណាមួយ ដើម្បីឲ្យបានផ្ដាច់បាបរបស់ពួកគេ » ( នីហ្វៃទី2 25:26 ) ។

36. សូមមើលកាឡាទី 3:29, គោលលទ្ធិនិងសេចក្ដីសញ្ញា 86:8—11 ។

37. គំនិតនេះមានទំនាក់ទំនងនឹងយើងថា ៖ « ជាច្រើនតំណបន្ទាប់ពី ព្រះមែស៊ីទ្រង់នឹងសម្ដែងរូបអង្គទ្រង់ឲ្យកូនចៅមនុស្សឃើញ ខណៈនោះភាពពោរពេញនៃដំណឹងល្អរបស់ព្រះមែស៊ី នឹងត្រូវបានមកដល់ពួកសាសន៍ដទៃ ហើយពីពួកសាសន៍ដ៏ទៃនឹងត្រូវបានមកដល់សំណល់នៃពូជយើងវិញ ---ហើយនៅថ្ងៃនោះសំណល់នៃពូជយើងនឹងបានដឹងថា ពួកគេជាវង្សអ៊ីស្រាអែល ហើយថាពួកគេជារាស្ត្រដែលនៅក្នុងសេចក្ដីសញ្ញានៃព្រះអម្ចាស់ ហើយខណៈនោះ ពួកគេនឹងបានដឹង ហើយនឹងបានការចេះដឹងអំពីពួកអយ្យកោរបស់ពួកគេ ហើយនឹងបានការចេះដឹងអំពីដំណឹងល្អនៃព្រះដ៏ប្រោសលោះរបស់ពួកគេ ជាដំណឹងល្អដែលទ្រង់បានផ្សាយដល់ពួកអយ្យកោគេដែរ ហេតុដូច្នោះហើយ ពួកគេនឹងបានការចេះដឹងអំពីព្រះដ៏ប្រោសលោះរបស់ពួកគេ និងគ្រប់ន័យទាំងឡាយនៃគោលលទ្ធិរបស់ទ្រង់ ដើម្បីឲ្យពួកគេអាចដឹងថា ត្រូវតែមករកទ្រង់ ទើបនឹងបានសង្គ្រោះ » ( នីហ្វៃទី1 15:13—14 ) ។

38. សូមមើលអេសាយ 55:3, យេរេមា 31:33, រ៉ូម 2:15, កូរិនថូសទី2 3:2—3, ហេព្រើរ 10:16 ។

39. សូមមើលទំនុកតម្កើង 95:7, 100:3, យេរេមា 24:7, 31:33,32:38, អេសេគាល 11:20, 37:23, 27, សាការី 8:8, កូរិនថូសទី2 6:16, ហេព្រើរ 8:10 ។

40. ម៉ូសាយ 2:41 ។